សេចក្ដីថ្លែងការណ៍

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
អំពីក្រសួងធម្មការពុំបានបំពេញកិច្ចការឲ្យស្របតាមមុខនាទីរបស់ខ្លួន

Website: www.hoksavann.org

ថ្ងៃទី៦ ធ្នូ ២០០៤

ក្រសួងធម្មការជាផ្នែកមួយរបស់រាជរដ្ឋាភិបាលខ្មែរ បង្កើតឡើងទទួលបន្ទុកកិច្ចការសាសនា ដែលមានទំនាក់ទំនងជាមួយក្រសួងព្រះសង្ឃរាជនៃផ្លូវពុទ្ធចក្រ ។ ក្រសួងធម្មការនៃប្រទេសកម្ពុជាខុសគ្នាពីក្រសួងធម្មការនៅប្រទេសថៃ គឺក្រសួងធម្មការនៅប្រទេសថៃមានមុខងារត្រឹមតែធ្វើជាលេខាធិការរបស់ថេរសមាគមថៃប៉ុណ្ណោះ ពុំមានអំណាចត្រួតត្រាលើព្រះសង្ឃឡើយ គណៈសង្ឃថៃមានអំណាចចាត់ចែងកិច្ចការសាសនាដោយឯករាជ្យ ចំណែកក្រសួងធម្មការនៅប្រទេសខ្មែរ ជាតំណាងរាជរដ្ឋាភិបាលខ្មែរទាក់ទងមកព្រះសង្ឃ ហើយមានពេលខ្លះហាក់ដូចជាត្រួតត្រាលើព្រះសង្ឃ បង្គាប់ឲ្យព្រះសង្ឃធ្វើតាមក្រសួងនេះផង ។

ពាក្យថាធម្មការ ប្រែថាកិច្ចការប្រកបដោយធម៌ គឺគប្បីជ្រើសរើសបុគ្គលិកអ្នកធ្វើការតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម ឲ្យជាអ្នកចេះដឹងផ្លូវធម៌ព្រះពុទ្ធសាសនា និងមានចរិយាល្អផង ទើបការងារក្រសួងនេះមានដំណើរល្អស្របតាមមុខងារនៃក្រសួងនេះ ។ ផ្ទុយទៅវិញ បុគ្គលិកនៃក្រសួងនេះត្រូវបានជ្រើសរើសដោយបក្សពួក ដោយសាច់ញាតិ ពុំបានជ្រើសរើសតាមសមត្ថភាពនិងតាមគុណសម្បត្តិទេ ។ ក្រសួងនេះជាក្រសួងសាសនា គឺព្រះពុទ្ធសាសនា ប៉ុន្តែបុគ្គលិកនៃក្រសួងនេះភាគ ច្រើនពុំចេះព្រះពុទ្ធសាសនា ជាពិសេសរដ្ឋមន្ត្រីនៃក្រសួងនេះតែម្តង ពុំចេះព្រះពុទ្ធសាសនា ។ បើពុំចេះព្រះពុទ្ធសាសនា ហើយឲ្យកាន់ការព្រះពុទ្ធសាសនាពុំអាចធ្វើ ឲ្យព្រះពុទ្ធសាសនាលូតលាស់ចំរើនបានឡើយ ។ មិនត្រឹមតែពុំចេះធម៌វិន័យរបស់ព្រះពុទ្ធសាសនា ដែលជាមុខនាទីរបស់ខ្លួនដែលត្រូវតែចេះនោះទេ ថែមទាំងចំណេះពិធីកម្ម របៀបថ្វាយបង្គំព្រះរតនត្រ័យឲ្យសមរម្យតាមទំនៀមទម្លាប់អ្នកកាន់ព្រះពុទ្ធសាសនា ក៏អនុវត្តឆ្គងដែរ ។ នៅប្រទេសភូមា រដ្ឋមន្ត្រីក្រសួងធម្មការចេះព្រះពុទ្ធសាសនាច្បាស់លាស់ ថែមទាំងប្រតិបត្តិព្រះពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់មា នអនុវត្តផ្លូវវិបស្សនាអប់រំចិត្តផង ។

សកម្មភាពខ្លះដែលបុគ្គលិកក្រសួងធម្មការបានប្រព្រឹត្តឆ្គងពុំស្របតាមពាក្យថាធម្មការ ទៅជាអធម្មការ គឺជាអំពើពុំប្រកបដោយធម៌ ក្លាយទៅជាអ្នកប្រព្រឹត្តអំពើពុករលួយដូចជាក្រសួងនានាដែរនោះ គឺសមណសិស្ស សមណនិស្សិតមានបច្ច័យផ្តល់ជូនក្រសួងធម្មការ សមណសិស្ស សមណនិស្សិតនោះពិតជាប្រឡងជាប់ ។ ព្រះសង្ឃដែលត្រូវការហត្ថលេខាពីក្រសួងធម្មការ ដើម្បីធ្វើសម្ភាសន៍មកបរទេស មានមកសហរដ្ឋអាមេរិកជាដើម មានការពិបាកណាស់ ដោយអ្នកបោះត្រាបង្គាប់យកបច្ច័យគ្មានកំណត់តាមច្បាប់ឲ្យបានត្រឹមត្រូវ ។ ព្រះសង្ឃសុំច្បាប់បង្កើតសមាគមក៏លំបាកណាស់ដែរ គឺអាតូចស៊ីដោយតូច អាធំស៊ីដោយធំ គឺស៊ីតាំងពីថ្នាក់ភូមិថ្នាក់ឃុំថ្នាក់ស្រុករហូតក្រសួងធម្មការ បើពុំដូច្នោះទេច្បាប់សមាគមនោះពុំអាចចេញរួចឡើយ ។ បុគ្គលិកក្រសួងធម្មការនៅប៉ោយប៉ែតបានជិះម៉ូតូទៅចែកសំបុត្រ និមន្តព្រះសង្ឃប្រជុំ តែបានទារបច្ច័យជាតម្លៃថ្លៃសាំងពីព្រះសង្ឃដែលខ្លួនប្រគេនលិខិតនោះ ។ នេះជារឿងដ៏ចម្លែកមួយ ព្រោះការប្រគេនលិខិតនិមន្តព្រះសង្ឃប្រជុំ ជាភារកិច្ចរបស់ខ្លួន តែការចំណាយទៅជាទារពីព្រះសង្ឃទៅវិញ គេដឹងហើយថាប្រាក់បៀវត្សនៃបុគ្គលិកអ្នករាជការមានកម្រិតទាប ពុំអាចផ្គត់ផ្គង់គ្រួសារបានឡើយ ម្លោះហើយត្រូវតែឆ្លៀតរកនាយអាយដើម្បីបំពេញកង្វះខាតនេះ ប៉ុន្តែកុំឲ្យការប្រព្រឹត្តអំពើពុករលួយនោះក្លាយទៅជាឧបសគ្គនៅក្នុងការលូតលាស់របស់ប្រទេស ។

ក្នុងរដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជាបច្ចុប្បន្នចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដែលរដ្ឋត្រូវតែការពារនិងឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យចំរើនលូតលាស់ដូចជាបញ្ជូនសមណនិស្សិតទៅសិក្សានៅប្រទេសដែលកាន់ព្រះពុទ្ធសាសនាជាដើម ។ តាមដំណឹងថា ព្រះសង្ឃសមណនិស្សិតដែលទៅសិក្សានៅបរទេសភាគច្រើន លោកដោះស្រាយដោយខ្លួនលោក គ្មានការឧបត្ថម្ភពីក្រសួងធម្មការឡើយ ។ អង្គខ្លះសិក្សាចប់ត្រឡប់មកវិញ គ្មានការទទួលអបអរសាទរពីក្រសួងធម្មការឡើយ ដោយពុំបានចាត់តាំងឲ្យព្រះសង្ឃទាំងនោះមានតំណែងណាមួយ មានធ្វើជាសាស្ត្រាចារ្យជាដើម ដើម្បីអភិវឌ្ឍន៍ព្រះពុទ្ធសាសនាឡើយ ។ ការប្រកាន់បក្សពួក ហើយដាក់ព្រះសង្ឃដែលមានចំណេះតិចខាងព្រះពុទ្ធសាសនាឲ្យកាន់ការ ពុំអាចធ្វើឲ្យព្រះពុទ្ធសាសនាចំរើនលូតលាស់បានឡើយ ។ រឿងមួយទៀតដែលគួរចាប់អារម្មណ៍ អ្នកកាន់សាសនាគ្រិស្តមានចំនួនតិចណាស់នៅប្រទេសកម្ពុជា តាមពត៌មានថា មានមួយភាគរយ ចុះហេតុអ្វីបានជាអនុញ្ញាតឲ្យកសាងវិហារគ្រិស្តសាសនាច្រើនម្ល៉េះ តើបណ្តាលមកពីហេតុអ្វី ? គេនិយាយថា នៅប្រទេសកម្ពុជាឲ្យតែមានដុល្លារ គេធ្វើអ្វីក៏បានដែរ ដូច្នេះបញ្ជាក់ថា ព្រះវិហារគ្រិស្តសាសនាមានចំនួនច្រើន តែកាន់មានចំនួនតិចនោះ គេអាចចោទថា ក្រសួងធម្មការប្រព្រឹត្តអំពើពុករលួយ ទទួលសំណូកជាដុល្លារ ឲ្យគេមកសម្លាប់វប្បធម៌របស់ខ្លួន ដែលខ្លួនត្រូវការពារនោះទៅវិញ ។

ពេលនេះ ភារកិច្ចជាចម្បងរបស់ក្រសួងធម្មការ គប្បីឈបប្រព្រឹត្តអំពើណា ដែលមិនប្រកបដោយធម៌ ហើយអនុវត្តនូវរាល់កិច្ចការ ដែលនាំឲ្យព្រះពុទ្ធសាសនាមានភាពរឹងមាំនិងលូតលាស់ទៅមុខ គឺរក្សាជំនឿរបស់ប្រជាពលរដ្ឋខ្មែរ គឺព្រះពុទ្ធសាសនាឲ្យបានគង់វង់ ស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជាដែលចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។៚